**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១០៩១ សហវ-ប្រក

## ប្រកាស

## ស្តីពី

## ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

### សម្រេច

**ប្រការ១.-**

ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើងដោយប្រកាសលេខ ២៩០ សហវ.ប្រក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៣ ត្រូវបានកែសម្រួលដូចខាងក្រោម។

**ប្រការ២.-**

ត្រូវបានបង្កើតក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានានីត្យានុកូលភាព សង្គតិភាព និងសុខដុមភាព នៃការតាក់តែងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងធានាបាននូវប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិ នៃ



លេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
92. Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ការគ្រប់គ្រងការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ដែលជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងចូលរួមចំណែកដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**ប្រការ៣.-**

ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានតួនាទីនិងភារកិច្ចដូចតទៅ ÷

- ធានាសង្គតិភាពរវាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសង្គតិភាពជាមួយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត
- ធានាភាពរលូននិងប្រសិទ្ធភាព ក្នុងការបកស្រាយនិងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងសម្រេចលើសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងសេចក្តីព្រាងវិសោធនកម្មបទប្បញ្ញត្តិទាំងឡាយ ក្រៅពីបទប្បញ្ញត្តិដែលត្រូវធ្វើឡើងជាប្រចាំនិងទៀងទាត់ នៅក្នុងសមត្ថកិច្ចក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងសម្រេចលើសំណើបកស្រាយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ជាសមត្ថកិច្ចក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដែលត្រូវបានដាក់ឱ្យអនុវត្ត ក្នុងក្របខណ្ឌសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងសម្រេចលើខ្លឹមសារនៃសេចក្តីព្រាងកិច្ចសន្យាសំខាន់ៗ ដែលមានវេទយិតភាពខ្ពស់ ឬដែលមិនមែនជាកិច្ចសន្យាដែលត្រូវធ្វើឡើងក្នុងក្របខណ្ឌការងារប្រចាំថ្ងៃ នៅក្នុងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងសម្រេចលើការដោះស្រាយបណ្តឹងឬវិវាទនានា ដែលជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងសម្រេចលើសំណើចាត់តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការការពារផលប្រយោជន៍ផ្លូវច្បាប់របស់ក្រសួង ជាមួយស្ថាប័នពាក់ព័ន្ធនានា
- ពិនិត្យនិងសម្រេចដាក់ឱ្យប្រើជាផ្លូវការនូវកម្រងអត្ថបទច្បាប់និងលិខិតបទដ្ឋានគតិយុត្ត តាមវិស័យជំនាញ ក្នុងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងសម្រេចដាក់ឱ្យអនុវត្តជាផ្លូវការនូវកម្រងលិខិតរដ្ឋបាលគំរូនិងកិច្ចសន្យាគំរូ ក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ចាត់ចែងឱ្យមានការចូលរួម ពិនិត្យ និងពិភាក្សាជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ឬក្នុងកិច្ចប្រជុំអន្តរក្រសួង លើការងាររៀបចំតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ។

**ប្រការ៤.-**

ក្រុមប្រឹក្សានីតិកម្ម ត្រូវមានសមាសភាពដូចខាងក្រោម ÷

- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធាន
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

- អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានចំណាយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- អគ្គាធិការនៃអគ្គាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម សមាជិកអចិន្ត្រៃយ៍។

**ប្រការ៥._**

អនុប្រធាននិងសមាជិកនៃក្រុមប្រឹក្សានីតិកម្ម ត្រូវចូលរួមប្រជុំ តាមការកោះអញ្ជើញរបស់ប្រធាន។

ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ អនុប្រធានត្រូវកោះអញ្ជើញ និងដឹកនាំការប្រជុំជំនួស តាមការផ្ទេរសិទ្ធិរបស់ប្រធាន។

**ប្រការ៦._**

ក្រុមប្រឹក្សានីតិកម្ម ប្រើប្រាស់នាយកដ្ឋាននីតិកម្ម នៃអគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាន។

ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៧._**

លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ត្រូវបំពេញមុខងារនិងភារកិច្ចដូចខាងក្រោម ÷

- ធ្វើជាសេនាធិការបច្ចេកទេសច្បាប់ និងរដ្ឋបាលជូនក្រុមប្រឹក្សានីតិកម្ម
- រៀបចំ និងសម្របសម្រួលកិច្ចប្រជុំរបស់ក្រុមប្រឹក្សានីតិកម្ម
- ធ្វើកំណត់ហេតុ និងរៀបចំរបាយការណ៍នៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សានីតិកម្ម
- បូកសរុបរបាយការណ៍ស្តីពីការរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងសេចក្តីព្រាងវិសោធនកម្មពាក់ព័ន្ធ សម្រាប់ដាក់ជូនក្រុមប្រឹក្សានីតិកម្ម ពិនិត្យនិងសម្រេច
- លើកសំណើអំពីការបកស្រាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនក្រុមប្រឹក្សានីតិកម្ម ពិនិត្យនិងសម្រេច
- បូកសរុបរបាយការណ៍ស្តីពីការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់ដាក់ជូនក្រុមប្រឹក្សានីតិកម្ម ពិនិត្យនិងវាយតម្លៃ ឬចាត់វិធានការបន្ត
- បូកសរុបរបាយការណ៍ស្តីពីខ្លឹមសារនៃសេចក្តីព្រាងកិច្ចសន្យាសំខាន់ៗ ជូនក្រុមប្រឹក្សានីតិកម្មពិនិត្យនិងសម្រេច
- លើកសំណើនិងផ្តល់អនុសាសន៍លើដំណោះស្រាយចំពោះពាក្យបណ្តឹង ឬវិវាទនានា ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនក្រុមប្រឹក្សានីតិកម្ម ពិនិត្យនិងសម្រេច
- លើកសំណើចាត់តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការការពារផលប្រយោជន៍ផ្លូវច្បាប់របស់ក្រសួង ជាមួយស្ថាប័នពាក់ព័ន្ធនានា ជូនក្រុមប្រឹក្សានីតិកម្ម ពិនិត្យនិងសម្រេច

- សិក្សាស្រាវជ្រាវនិងចងក្រងកម្រងអត្ថបទច្បាប់និងលិខិតបទដ្ឋានគតិយុត្ត តាមវិស័យជំនាញ ក្នុងសមត្ថកិច្ចរប ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនក្រុមប្រឹក្សានីតិកម្ម ពិនិត្យនិងសម្រេចដាក់ឱ្យប្រើជាផ្លូវការ
- សិក្សាស្រាវជ្រាវនិងចងក្រងកម្រងលិខិតរដ្ឋបាលគំរូ និងកិច្ចសន្យាគំរូ ដាក់ជូនក្រុមប្រឹក្សានីតិកម្ម ពិនិត្យ សម្រេចដាក់ឱ្យអនុវត្តជាផ្លូវការ ក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ផ្សព្វផ្សាយកម្រងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត តាមវិស័យជំនាញ កម្រងលិខិតរដ្ឋបាលគំរូ និងកម្រងកិច្ចសន្យា ដែលត្រូវបានសម្រេចដាក់ឱ្យប្រើឬអនុវត្ត ជាផ្លូវការដោយក្រុមប្រឹក្សានីតិកម្ម
- ចូលរួមពិនិត្យនិងពិភាក្សាជាមួយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ឬក្នុងកិច្ចប្រជុំអន្តរក្រសួង លើការងាររៀបចំត តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ តាមការចាត់តាំងរបស់ក្រុមប្រឹក្សានីតិកម្ម
- តម្កល់អត្ថបទគតិយុត្ត នៅក្នុងមជ្ឈមណ្ឌលឯកសារច្បាប់ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់គ្រងមជ្ឈមណ្ឌលឯកសារច្បាប់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បំពេញភារកិច្ចផ្សេងទៀត តាមការចាត់តាំងរបស់ប្រធានក្រុមប្រឹក្សានីតិកម្ម។

**ប្រការ៨.–**

ប្រកាសលេខ ២៩០ សហវ.ប្រក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រុមប្រឹក្សានីតិកម្មនៃក្រសួ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩.–**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការនៃអគ្គាធិការដ្ឋាន ក្រោមឱវា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសមាសភាពដូចមានចែងក្នុងប្រការ៤ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន_ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានី ខេត្ត
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ